ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

**សាលាដំបូងខេត្តកំពង់ស្ពឺ**
សាលក្រមព្រហ្មទណ្ឌលេខ ៨០ -ខ-
ចុះថ្ងៃទី០៦ ខែមករា ឆ្នាំ២០២១

# ក្នុងនាមប្រជារាស្ត្រខ្មែរ
# សាលាដំបូងខេត្តកំពង់ស្ពឺ

បានបើកសវនាការជាសាធារណៈនៅសាលាដំបូងខេត្តកំពង់ស្ពឺនាថ្ងៃទី០៤ ខែធ្នូ ឆ្នាំ២០២០ ដោយមានសមាសភាព ៖

**ចៅក្រមជំនុំជម្រះ**

លោក [redacted] អនុប្រធានសាលាដំបូងខេត្តកំពង់ស្ពឺ

**តំណាងអយ្យការ**

លោក [redacted] ព្រះរាជអាជ្ញារងនៃអយ្យការអមសាលាដំបូងខេត្តកំពង់ស្ពឺ

**ក្រឡាបញ្ជីសវនាការ**

លោកស្រី [redacted] ក្រឡាបញ្ជីសាលាដំបូងខេត្តកំពង់ស្ពឺ

-ដើម្បីជំនុំជម្រះលើសំណុំរឿងព្រហ្មទណ្ឌលេខ ៩៣៤ ចុះថ្ងៃទី០៨ ខែសីហា ឆ្នាំ២០២០ ដែលមានជនជាប់ចោទឈ្មោះ [redacted] លឹម ហៅ ប៉ឹម ភេទប្រុស អាយុ៥៥ឆ្នាំ ជនជាតិខ្មែរ សញ្ជាតិខ្មែរ មុខរបរធ្វើស្រែ សាសនាព្រះពុទ្ធ ទីកន្លែងកំណើតភូមិ[redacted] ខេត្តកំពង់ស្ពឺ ទីលំនៅបច្ចុប្បន្នភូមិ ត្រពាំងវែង ឃុំសំបូរ ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ ឪពុកឈ្មោះ [redacted] ចុង (រ) ម្តាយឈ្មោះ [redacted] ពេជ្រ (ស) ប្រពន្ធឈ្មោះ [redacted] ចន្ធូ(រ) មានកូន០៧នាក់ ជានិតិជន ទោសពីមុនគ្មាន។(ដីកាបង្គាប់ឃុំខ្លួនលេខ៨៧៩ ចុះថ្ងៃទី០៨ ខែសីហា ឆ្នាំ២០២០)

**<u>ជាប់ចោទពីបទ</u>៖** ហិង្សាដោយចេតនាមានស្ថានទម្ងន់ទោស ប្រព្រឹត្តនៅភូមិបង្កើយ ឃុំសំបូរ ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ កាលពីថ្ងៃទី០៥ ខែសីហា ឆ្នាំ២០២០ តាមបញ្ញត្តិមាត្រា២១៨ នៃក្រមព្រហ្មទណ្ឌ។

-មេធាវីឈ្មោះ [redacted] ការពារសិទ្ធិឲ្យជនជាប់ចោទ ។

-មេធាវីឈ្មោះ [redacted] ការពារសិទ្ធិឲ្យជនជាប់ចោទ ។

-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ម៉ុម ភេទស្រី អាយុ៤០ឆ្នាំ ជនជាតិខ្មែរ ទីលំនៅបច្ចុប្បន្នភូមិបង្កើយ ឃុំសំបូរ ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ ។



Scanned with CamScanner

រីឯរឿងហេតុមានដូចតទៅ ៖ កាលពីថ្ងៃទី០៥ ខែសីហា ឆ្នាំ២០២០ វេលាម៉ោង១៨ និង ១៤នាទី ស្ថិតនៅភូមិបង្កើយ ឃុំសំបូរ ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ មានករណីហិង្សាដោយចេតនា បង្កឡើងដោយជនជាប់ចោទឈ្មោះ [redacted] លីម (ហៅ ប៊ឹម) ភេទប្រុស អាយុ៥៥ឆ្នាំ បានយកកូនកាំបិត ចុងស្រួចចាក់ទៅលើជនរងគ្រោះឈ្មោះ [redacted] ម៉ុម ភេទប្រុស បណ្តាលឲ្យត្រូវចំឆ្អឹងជំនីផ្នែកខាងស្តាំ ហូរឈាមខ្លាំង និងបានក្រុមគ្រួសារជនរងគ្រោះបញ្ជូនទៅសម្រាកព្យាបាលនៅមន្ទីរពេទ្យលោកសង្ឃ ។ តាមចម្លើយសារភាពរបស់ជនជាប់ចោទខាងលើបានឆ្លើយថា នៅថ្ងៃកើតហេតុខ្លួនបានដើរទៅទិញម្ហូប នៅផ្ទះរបស់ឈ្មោះ [redacted] ផេន ពេលខ្លួនទៅដល់បានឃើញឈ្មោះ [redacted] ,ឈ្មោះ [redacted] សុភី និងឈ្មោះ ម៉ុម កំពុងអង្គុយផឹកស្រាថ្នាំ ក៏ហៅខ្លួនទៅផឹកជាមួយ ពេលផឹកបានបន្តិចស្រាប់តែឈ្មោះ ម៉ុម បបួលខ្លួនវាយគ្នា ខ្លួនក៏យល់ព្រមវាយគ្នា ។ឈ្មោះ ម៉ុម វាយខ្លួនត្រូវបីដៃចំស្មា ខ្លួនក៏ស្ទុះងើបដើរទៅយកកូនកាំបិតចុងស្រួចពីកន្លែងលក់បន្លែចាក់ទៅលើឈ្មោះ ម៉ុម ចាក់ចំឆ្អឹងជំនីផ្នែកខាងស្តាំ បណ្តាលឲ្យហូរឈាមខ្លាំង ។

-បានឃើញចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] លីម ហៅ ប៊ឹម ភេទប្រុស អាយុ ៥៥ឆ្នាំ បានឆ្លើយថា នៅថ្ងៃកើតហេតុនៅថ្ងៃទី០៥ ខែសីហា ឆ្នាំ២០២០ វេលាម៉ោងប្រហែល០៤ល្ងាច ខ្លួនបានផឹកស្រានៅផ្ទះឈ្មោះ ឡូត ដោយផឹកមានគ្នា ០៤នាក់ មានខ្លួន ,ឈ្មោះ ឡូត ,ឈ្មោះ [redacted] ភី និងឈ្មោះ [redacted] ម៉ុំ ដោយឈ្មោះ [redacted] ភី បានហៅខ្លួនចូលហូបស្រា ក្រោយមកខ្លួនហូបស្រាបានបីកែវ ស្រាប់តែឈ្មោះ [redacted] ម៉ុម បបួលខ្លួនវាយគ្នា ខ្លួនក៏ឆ្លើយយល់ព្រមវាយគ្នាជាមួយឈ្មោះ [redacted] ម៉ុម ដោយខ្លួនឆ្លើយនោះ ព្រោះខ្លួនគិតថាឈ្មោះ [redacted] ម៉ុម និយាយលេង ខ្លួនក៏និយាយលេងជាមួយគាត់ទៅ តែឈ្មោះ [redacted] ម៉ុំ បានវាយខ្លួនចំនួន ០២ ដៃ មួយដៃត្រូវចំស្មា និងមួយដៃទៀត ត្រូវចំចង្កា ខ្លួនដឹងថាខ្លួនវាយគ្នាជាមួយឈ្មោះ [redacted] ម៉ុំ មិនឈ្នះទេ ទើបខ្លួនក្រោកទៅយកកាំបិតចិតបន្លែចាក់ទៅលើឈ្មោះ [redacted] ម៉ុម មួយកាំបិតត្រង់ចង្កេះ (មិនបានដកកាំបិតចេញពីចង្កេះឈ្មោះម៉ុមទេ) ស្រាប់តែឈ្មោះ ឡូត បានវាយខ្លួនមួយដៃត្រូវគុម្ពត្រចៀក ហើយបានយកដំបងមកវាយត្រូវដៃមួយដំបងទៀត ។ ក្រោយមកឈ្មោះ [redacted] ភី បានឃាត់ឈ្មោះ ឡូត កុំឲ្យវាយខ្លួនទៀត រួចខ្លួនក៏ត្រឡប់ទៅផ្ទះវិញ។ នៅថ្ងៃដដែលនោះ វេលាម៉ោងប្រហែល០៧យប់ ក៏មានសមត្ថកិច្ចមកហៅខ្លួនទៅប៉ុស្តិ៍ រួចធ្វើរបាយការណ៍បញ្ជូនខ្លួនមកស្រុក ។ កន្លងមកខ្លួន និងឈ្មោះ [redacted] ម៉ុម មិនធ្លាប់មានទំនាស់ ជាមួយគ្នាទេ ។ ខ្លួនទទួលស្គាល់ថាពិត ជាបានយកកាំបិតចិត បន្លែចាក់ទៅលើឈ្មោះ [redacted] ម៉ុម មួយកាំបិតចំចង្កេះពិតប្រាកដមែន ។ ពេលដែលសមត្ថកិច្ចឃាត់ខ្លួន មិនមានដកហូតអ្វីទេ ខ្លួនបានដឹងកំហុសហើយសំណូមពរសូមឲ្យតុលាការជួយបន្ធូរទោសដល់ខ្លួនផង។

-បានឃើញចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ម៉ុម ភេទប្រុស បានឆ្លើយថា កាលពីថ្ងៃទី០៥ ខែសីហា ឆ្នាំ២០២០ វេលាម៉ោងប្រហែល០៥ល្ងាច ខ្លួនកំពុងផឹកស្រា នៅខាងក្រោយផ្ទះជាមួយឈ្មោះ ភី ,ឈ្មោះ ឡូត ,ឈ្មោះ ចាន់ ,ឈ្មោះ វឿន ,ឈ្មោះ ឈឹម និងឈ្មោះ លីម ហៅ ប៊ឹម ពេលកំពុងផឹកស្រាប់តែមានការជជែកគ្នា ពីរឿងដណ្តើមគ្នាច្រៀងខារ៉ាអូខេ ពេលនោះខ្លួនក៏ដើរចេញទៅផ្ទះស្រាប់តែឈ្មោះ លីម ហៅ ប៊ឹម បាននិយាយថាចង់រកវាយខ្លួន ពេលនោះខ្លួនក៏ដើរមកវិញ និងបានជជែកគ្នា ហើយបានវាយគ្នាមួយដៃទៅវិញទៅមក ហើយឈ្មោះ ចាន់ ក៏បានដឹកឈ្មោះ លីម ហៅ ប៊ឹម ទៅផ្ទះបាត់



Scanned with CamScanner

ទៅមួយសន្ទុះក្រោយមកឈ្មោះ [redacted] លីម ក៏បានជិះកង់មកវិញ រួចចុះដើរមកក្បែរខ្លួន និងទាញកូនកាំបិតពីក្នុងហោប៉ៅរបស់គាត់ចាក់មកលើខ្លួនត្រូវចំចង្កេះតែម្តង ពេលនោះខ្លួនមិនទាន់សន្លប់ទេហើយក៏មានគេចាប់ឈ្មោះ លីម ចេញទៅបាត់ទៅ ។ កន្លងមកខ្លួនមិនដែលមាន ទំនាស់អ្វីជាមួយឈ្មោះ [redacted] លីមទេ។ ចំពោះរបួសរបស់ខ្លួនព្យាបាលអស់ប្រហែល ៦.០០០.០០០(ប្រាំមួយលាន)រៀល ប៉ុន្តែពុំមានវិក័យបត្រទេ។ នៅក្នុងរឿងហេតុនេះដោយសារនៅថ្ងៃកើតហេតុខ្លួនមានរបួសមិនអាចដាក់ពាក្យបណ្តឹងបាន ក៏ឲ្យឪពុកខ្លួនដាក់ពាក្យបណ្តឹងជំនួស តែពេលនេះខ្លួនបានជាសះស្បើយ ហើយសូមតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីវិញ ព្រោះឪពុកខ្លួនឈ្មោះ [redacted] ម៉ី ដែលជាដើមបណ្តឹងគាត់ចាស់ជរាទៅហើយមិនអាចឡើងចុះមកតុលាការបានឡើយ ។ សូមទាមទារសំណងថ្លៃព្យាបាលរបួសចំនួន ៦.០០០.០០០ (ប្រាំមួយលាន) រៀល និងជម្ងឺចិត្តចំនួន ៥៤.០០០.០០០ (ហាសិបបួនលាន)រៀល ពីឈ្មោះ [redacted] លីម ហៅ ប៊ុម និងសូមឲ្យតុលាការផ្តន្ទាទោសតាមច្បាប់ ។

-បានឃើញចម្លើយរបស់សាក្សីឈ្មោះ [redacted] ភី ភេទប្រុស បានឆ្លើយថា ដោយកាលពីថ្ងៃទី០៥ ខែសីហា ឆ្នាំ២០២០ វេលាម៉ោងប្រហែល១៨ និង១៤ នាទី ខ្លួនបានហូបស្រានៅក្រោយផ្ទះ [redacted] ឡូត ជាមួយឈ្មោះ ចាន់ ,ឈ្មោះ [redacted] លីម ,ឈ្មោះ ឈឹម ,ឈ្មោះ សារឿន និងឈ្មោះ [redacted] មុំ ដែលរស់នៅភូមិជាមួយគ្នាពេលផឹកអស់១០កំប៉ុង ឈ្មោះ [redacted] មុំ និងឈ្មោះ [redacted] លីម ហៅ ប៊ុម បានទាស់ពាក្យសំដីគ្នា និងនិយាយពាក្យហ្មែងអញ ហើយក៏បានប្រតាយប្រតប់គ្នាទៅវិញទៅមក ពេលនោះខ្លួនក៏បានដើរចូលទៅជួយចាប់បំបែកពីគ្នា ចំណែកឈ្មោះ ចាន់ បានចាប់ឈ្មោះ [redacted] លីម ទៅផ្ទះទៅ ចំណែកខ្លួននៅអង្គុយហូបនៅទីនោះដដែល ពេលហូបបានប្រហែលកន្លះកំប៉ុងស្រាប់តែឃើញឈ្មោះ [redacted] លីម ហៅ ប៊ុម ជិះកង់មកវិញ ហើយដើរសំដៅទៅរកឈ្មោះ មុំ និងបានយកកូនកាំបិតចាក់ ទៅលើឈ្មោះ មុំ នៅក្រោមឆ្អឹងជំនីខាងឆ្វេងមួយ កាំបិតតែម្តង ។

-បានឃើញចម្លើយរបស់សាក្សីឈ្មោះ [redacted] ឡូត ហៅ ពៅ ភេទប្រុស បានឆ្លើយថា កាលពីថ្ងៃទី០៥ ខែសីហា ឆ្នាំ២០២០ វេលាម៉ោងប្រហែប្រាំល្ងាច ខ្លួនបានផឹកជាមួយបងប្អូន និងអ្នកជិតខាងជាប់របងគ្នានៅផ្ទះខ្លួនមានគ្នា ប្រហែលប្រាំមួយនាក់ មានឈ្មោះ [redacted] ភី ,ឈ្មោះ [redacted] ចាន់ ,ឈ្មោះ [redacted] ម៉ុម ,ឈ្មោះ ឆាំ ឈឹម និងឈ្មោះ [redacted] រឿន ផឹកមួយសន្ទុះឃើញឈ្មោះ ប៊ឹម ចូលមកផឹកជាមួយ ពេលផឹកជជែកគ្នាលេង និងមានខារ៉ាអូខេច្រៀងទៀតផង ផឹកបានមួយសន្ទុះស្រាប់តែឈ្មោះ ប៊ឹម និយាយថា (ដូចចង់វៃអាមុំដល់ហើយ) ពេលនោះក៏ឃើញឈ្មោះ មុំ ដើរចេញពីកន្លែងផឹក ហើយឈ្មោះ ប៊ឹម ក៏ដើរតាមពីក្រោយទៅវៃប្រតាយប្រតប់គ្នា បន្ទាប់មកឈ្មោះ យុត ចាន់ បានឃាត់ហើយជូនឈ្មោះ ប៊ឹម ទៅផ្ទះ មួយសន្ទុះឈ្មោះ ប៊ឹម ក៏ជិះកង់ត្រឡប់មកវិញ ក៏យកកាំបិតចុងស្រួចមក ចាក់លើឈ្មោះ [redacted] ម៉ុម មួយកាំបិតចំប្រឡោះ ឆ្អឹងជំនីភ្លាមៗនោះមានគេជួយឃាត់ ចំណែកខ្លួនក៏បានយកឈ្មោះ [redacted] ម៉ុម ទៅមន្ទីរពេទ្យ ។ ខ្លួនមិនដឹងថាឈ្មោះ ប៊ឹម និងឈ្មោះ [redacted] ម៉ុម មានទំនាស់អ្វីជាមួយគ្នាពីមុនមកទេ ។

-បានឃើញចម្លើយសាក្សីឈ្មោះ [redacted] ឃឿន ភេទស្រី អាយុ៣៧ឆ្នាំ បានឆ្លើយថា កាលពីថ្ងៃទី០៥ ខែសីហា ឆ្នាំ២០២០ វេលាម៉ោងប្រហែល០៥ល្ងាច ប្តីនាងខ្លួនបានផឹកស្រាជាមួយបង ប្អូនមានគ្នាប្រហែល

ប្អូនទៅប្រាំនាក់ ផឹកបានមួយសន្ទុះស្រាប់តែមានឈ្មោះ ប៊ឹម ដែលរស់នៅក្នុងភូមិជាមួយគ្នាចូលមកផឹកនៅផ្ទះខ្លួនដែរ ដោយមិនមាននរណាហៅគាត់នោះទេ ពេលនោះមានការជជែកលេងធម្មតា មួយសន្ទុះប្ដីខ្លួនបានដើរចូលទៅក្នុងផ្ទះបម្រុងថានឹងចូលសម្រាន្តតែឈ្មោះ ប៊ឹម បាននិយាយថា ចង់វ៉ៃអាម៉ុមដល់ហើយ បន្ទាប់មកប្ដីខ្លួននិយាយតបវិញថា (មកផ្ទះខ្ញុំហើយ ចង់វ៉ៃខ្ញុំទៀត) ហើយប្ដីខ្លួន និយាយទៀតថា (បើវ៉ៃដៃ និង ដៃមិនខ្លាចទេ) បន្ទាប់មកក៏វ៉ៃគ្នាបានមួយដៃម្នាក់ ហើយក៏មានគេឃាត់ រួចបងខ្លួនបានឌុបឈ្មោះ ប៊ឹម ទៅផ្ទះ ព្រោះឃើញគាត់មានសភាពស្រវឹង ស្រាប់តែមួយសន្ទុះឈ្មោះ ប៊ឹម ក៏បានជិះកង់ត្រឡប់មកវិញ ហើយចូលក្នុងកន្លែងផឹក ពេលនោះគេសួរនាំអ្វីក៏គាត់មិនឆ្លើយដែររួច ឈ្មោះ ប៊ឹម បានដកកាំបិតចេញពីហោប៉ៅ រួចចូលមកចាក់ប្ដីខ្លួនមួយកាំបិតចិតបន្លែ ចំចង្កេះខាងស្ដាំ ពេលនោះបងជីដូនមួយខ្លួន បានក្រវៀសដៃឈ្មោះ ប៊ឹម ចេញនឹងបានវាយឈ្មោះ ប៊ឹម ប្រហែលបីបួនដៃ ភ្លាមៗនោះខ្លួនឃើញគេចាក់ប្ដីក៏សន្លប់បាត់ទៅ ។ ពេលភ្ញាក់ដឹងខ្លួននៅផ្ទះ ចំណែកប្ដីខ្លួនគឺគេបញ្ជូនទៅមន្ទីរពេទ្យនៅកំពង់ស្ពឺ ដោយមិនទុកចិត្តគេក៏បញ្ជូនគាត់ទៅពេទ្យលោកសង្ឃ នៅភ្នំពេញ ។ ប្ដីខ្លួន និង ឈ្មោះ ប៊ឹម មិនដែលមានទំនាស់អ្វីទេ ។

-បានឃើញចម្លើយសាក្សីឈ្មោះ [redacted] ចាន់ ភេទប្រុស បានឆ្លើយថា កាលពីថ្ងៃទី០៥ ខែសីហា ឆ្នាំ២០២០ វេលាម៉ោង១៨ និង១៤នាទី ខ្លួនបានចូលហូបស្រានៅផ្ទះឈ្មោះ [redacted] ឡុត ជាមួយ [redacted] ភី ឈ្មោះ [redacted] លីម ,ឈ្មោះ [redacted] ឈឹម ,ឈ្មោះ [redacted] សារឿន និងឈ្មោះ [redacted] មុំ ដែលរស់នៅភូមិជាមួយគ្នា ពេលផឹកអស់ពីរកំប៉ុងស្រាប់តែលឺសូរឈ្មោះ [redacted] មុំ និងឈ្មោះ [redacted] លីម ហៅ ប៊ឹម ជជែកគ្នា រឿងដណ្ដើមក្បាលមេក្រូ ហើយពេលនោះលឺឈ្មោះ [redacted] មុំ ហៅ ស៊ុយ លីម ទើបមានរឿងជជែកគ្នា ហើយឈ្មោះ [redacted] លីម បាននិយាយថា (ចង់វាយអាមុំដល់ហើយ) ពេលនោះអ្នកទាំងពីរក៏បានដើរ ចេញពីកន្លែងផឹកមកវាយគ្នាទៅវិញទៅ មកហើយខ្លួនក៏បានចូលចាប់ឈ្មោះ [redacted] លីម ហៅ ប៊ឹម និងដឹកគាត់ទៅផ្ទះវិញ បន្ទាប់មកខ្លួនក៏បានទៅផ្ទះខ្លួនវិញទៅ មិនបានត្រឡប់មកកន្លែងផឹកស៊ីវិញទេ ។ នៅក្នុងរឿងនេះ ខ្លួនបានដឹងរឿងតែប៉ុណ្ណឹងទេ។

-បានឃើញរបាយការណ៍សំយោគលេខ ៨៨/២០ រ.ប.ក ចុះថ្ងៃទី០៧ ខែសីហា ឆ្នាំ២០២០ របស់ការិយាល័យនគរបាលព្រហ្មទណ្ឌកម្រិតធ្ងន់ នៃស្នងការនគរបាលខេត្តកំពង់ស្ពឺ ។

-បានឃើញដីកាសន្និដ្ឋានស្ថាពរលេខ ៨៣៨១ អ.ក ចុះថ្ងៃទី០៨ ខែតុលា ឆ្នាំ២០២០ របស់តំណាងអយ្យការអមសាលាដំបូងខេត្តកំពង់ស្ពឺ។

-បានឃើញដីកាដំណោះស្រាយលេខ ១៣៤០ ចុះថ្ងៃទី១២ ខែតុលា ឆ្នាំ២០២០ របស់ចៅក្រមស៊ើបសួរ។

-បានឃើញដីកាចាត់តាំងចៅក្រមជំនុំជម្រះលេខ ១៦០៥ ចុះថ្ងៃទី០៨ ខែសីហា ឆ្នាំ២០២០ ។

<u>មេធាវីធ្វើសេចក្ដីសន្និដ្ឋានថា៖</u> ដោយជនជាប់ចោទមានសភាពស្រវឹងខ្លាំងបាត់បង់ការគ្រប់គ្រង ទើបបានប្រព្រឹត្តបទល្មើសដោយអចេតនា អាស្រ័យហេតុនេះក្នុងនាមខ្ញុំជាមេធាវីការពារក្ដីឲ្យជនជាប់ចោទ សុំសំណូមពរលោកចៅក្រមជំនុំជម្រះមេត្តាបន្ធូរបន្ថយទោសដល់កូនក្ដីខ្ញុំបាទផងដែលបានប្រព្រឹត្តកំហុសដោយអចេតនា ។

តំណាងអយ្យការធ្វើសេចក្តីសន្និដ្ឋានថា៖ ក្រោយពីបានធ្វើការសួរដេញដោលនាពេលសវនាការនេះ រួចឃើញថា ជនជាប់ចោទពិតជាប្រព្រឹត្តបទល្មើសហិង្សាមានស្ថានទម្ងន់ទោស តាមបញ្ញត្តិមាត្រា ២១៨ នៃក្រមព្រហ្មទណ្ឌ ដូចការចោទប្រកាន់មែន ដូច្នេះស្នើសុំឲ្យតុលាការសម្រេច និងផ្តន្ទាទោសជននោះតាមច្បាប់ ។

## សាលាដំបូងខេត្តកំពង់ស្ពឺ

ក្រោយពីបានស្តាប់ចម្លើយរបស់ជនជាប់ចោទ

ក្រោយពីបានស្តាប់ចម្លើយរបស់ដើមបណ្តឹង

ក្រោយពីបានស្តាប់ចម្លើយសាក្សី

ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវី

ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការ

ក្រោយពីបានពិចារណាត្រឹមត្រូវតាមច្បាប់រួចមក

## សំអាងហេតុ

១/.យោងតាមរបាយរបស់មន្ត្រីនគរបាលយុត្តិធម៌ ,ចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] លីម ហៅ ប៊ឹម និងចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ម៉ុម ព្រមទាំងចម្លើយរបស់សាក្សីជាច្រើននាក់ ឃើញថាមានភាពស៊ីសង្វាក់គ្នា ដោយមុនពេលកើតហេតុជនជាប់ចោទឈ្មោះ ស៊ុយ លីម បានផឹកស្រាជាមួយនឹងជនរងគ្រោះឈ្មោះ [redacted] ម៉ុម ក្នុងពេលនោះពួកគេទាំងពីនាក់បានឈ្លោះប្រកែកគ្នា និងបានប្រតាយប្រតប់គ្នាទៀតផង បន្ទាប់មកជនជាប់ចោទឈ្មោះ [redacted] លីម បានធ្វើសកម្មភាពយកកាំបិតចិតបន្លែចាក់ទៅលើរងគ្រោះឈ្មោះ [redacted] ម៉ុម ចំនួន០១កាំបិត ត្រូវចំចង្កេះបណ្តាលឲ្យរងរបួសពិតប្រាកដមែន។ ដូច្នេះអំពើរបស់ជនជាប់ចោទឆ្លុះបញ្ចាំងពីចេតនាទុច្ចរិតក្នុងការប្រព្រឹត្តបទល្មើស ហិង្សាដោយចេតនាមានស្ថានទម្ងន់ទោស តាមបញ្ញត្តិមាត្រា២១៨ នៃក្រមព្រហ្មទណ្ឌ។

២/.ជនត្រូវចោទឈ្មោះ [redacted] លីម បានទទួលស្គាល់ថាខ្លួនពិតបានប្រព្រឹត្តដូចការចោទប្រកាន់មែន និងបានដឹងអំពីកំហុសដែលខ្លួនបានធ្វើហើយ។

៣/.ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ម៉ុម បានឆ្លើយថា ខ្លួនព្យាបាលរបួសអស់ចំនួន ៦.០០០.០០០ (ប្រាំមួយលាន) រៀល តែពុំមានវិក័យប័ត្រទេ និងទាមទារសំណងជម្ងឺចិត្តចំនួន ៥៤.០០០.០០០ (ហាសិបបួនលាន)រៀល ។

៤/.មានភស្តុតាង និងពិរុទ្ធភាពគ្រប់គ្រាន់ដាក់បន្ទុកលើជនជាប់ចោទឈ្មោះ [redacted] លីម ពីបទហិង្សាដោយចេតនាមានស្ថានទម្ងន់ទោស ប្រព្រឹត្តនៅភូមិបង្កើយ ឃុំសំបូរ ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ តាមបញ្ញត្តិមាត្រា ២១៨ នៃក្រមព្រហ្មទណ្ឌ កាលពីថ្ងៃទី០៥ ខែសីហា ឆ្នាំ២០២០ ។

## ហេតុដូច្នេះមិនិច្ឆ័យសេចក្តី

១/.ផ្តន្ទាទោសលើជនជាប់ចោទឈ្មោះ [redacted] លីម ហៅ ប៊ឹម ភេទប្រុស អាយុ៥៥ឆ្នាំ ជនជាតិខ្មែរ ដាក់ពន្ធនាគារចំនួន ០២(ពីរ)ឆ្នាំ និង០៦ (ប្រាំមួយ)ខែ ប៉ុន្តែត្រូវអនុវត្តទោសក្នុងពន្ធនាគារចំនួន ០១(មួយ)ឆ្នាំ និង០៦ (ប្រាំមួយ)ខែ ចំណែកទោសសល់ពីនេះជាទោសព្យួរធម្មតា ពីបទ ហិង្សាដោយចេតនាមានស្ថាន

ទម្ងន់ទោស ប្រព្រឹត្តនៅភូមិបង្កើយ ឃុំសំបូរ ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ កាលពីថ្ងៃទី០៥ ខែសីហា ឆ្នាំ២០២០ តាមមាត្រា ២១៨ នៃក្រមព្រហ្មទណ្ឌ។

២/.បង្គាប់ឲ្យជនជាប់ចោទឈ្មោះ [redacted] លីម ហៅ ប៊ីម សងសំណងការខូចខាត និងជម្ងឺចិត្តចំនួន ១៥.០០០.០០០ (ដប់ប្រាំលាន) រៀល ទៅឲ្យដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ម៉ុម ។

៣/.សាលក្រមនេះជំនុំជម្រះជាសាធារណៈនិងប្រកាសជាសាធារណៈនៅថ្ងៃទី០៦ ខែមករា ឆ្នាំ ២០២១ ចំពោះមុខជនជាប់ចោទ និងចំពោះមុខដើមបណ្តឹងរដ្ឋប្បវេណី ។

សម្រេចបើកផ្លូវប្តឹងទាស់ និងប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់។

ក្រឡាបញ្ជី ចៅក្រមជំនុំជម្រះ

ហត្ថលេខ និងត្រា [redacted] ហត្ថលេខា និងត្រា [redacted]

---

បានចម្លងចេញត្រឹមត្រូវតាមច្បាប់ដើម។

ថ្ងៃ...៣កើត...ខែ...បុស្ស...ឆ្នាំជូត ទោស័ក ព.ស២៥៦៤

កំពង់ស្ពឺ,ថ្ងៃទី...០៣...ខែ...មេសា ឆ្នាំ២០២១

បានឃើញ

ចៅក្រមជំនុំជម្រះ

[redacted]

ក្រឡាបញ្ជី

[redacted]